# GCJAC

ក្រុមប្រឹក្សាយុត្តិធម៌ព្រហ្មទណ្ឌ **GCJAC**

តាមដាន ពិនិត្យឡើងវិញ វិភាគ អប់រំ ផ្តល់យោបល់ រាយការណ៍។

## គោលបំណងរបស់ **GCJAC** គឺដើម្បី៖

**តាមដាន**

កំណត់ និងដោះស្រាយបញ្ហានានានៅទូទាំងវិស័យយុត្តិធម៌

**ពិនិត្យឡើងវិញ**

តាមដាន ពិនិត្យ និងវាយតម្លៃករណីនានា

**វិភាគ**

ធ្វើការសិក្សាក៏ដូចជាកំណត់គំរូ និន្នាការ និងបញ្ហាជាលក្ខណៈប្រព័ន្ធ

**អប់រំ**

តស៊ូមតិ និងចូលរួមជាមួយស្ថាប័ន និងទីភ្នាក់ងារនានាហើយកំណត់វិធីសាស្រ្តផ្សេងក្នុងការដោះស្រាយបទឧក្រិដ្ឋ

**ផ្តល់យោបល់**

ធ្វើការនៅទូទាំងប្រព័ន្ធយុត្តិធម៌រួមទាំង GPD នឹងតុលាការ

**រាយការណ៍**

ប្រាស្រ័យទាក់ទងគ្នាតាមរយៈរបាយការណ៍ទៀងទាត់និងទំនាក់ទំនងជាមួយសាធារណជន

ក្រុមប្រឹក្សាត្រួតពិនិត្យសហគមន៍ប៉ូលិស (**PCRB**) គឺជាអនុគណៈកម្មាធិការរបស់ **GCJAC** ។ **PCRB** គឺជាក្រុមប្រឹក្សាយោបល់ដែលមានសមាជិកជាច្រើនមកពីសហគមន៍ **Greensboro** ។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការពិនិត្យឡើងវិញ វាយតម្លៃ និងរាយការណ៍អំពីការស៊ើបអង្កេតរដ្ឋបាល និងលទ្ធផលរកឃើញនៃផ្នែកស្តង់ដាវិជ្ជាជីវៈរបស់ក្រសួងប៉ូលីស **Greensboro (PSD)** ទាក់ទងនឹងការចោទប្រកាន់ពីបទប្រព្រឹត្តមិនត្រឹមត្រូវប្រឆាំងនឹងសមាជិកដែលបានស្បថចូលកាន់តំណែងនៅក្រសួងប៉ូលីស **Greensboro** ។

GREENSBORO
NORTH CAROLINA

## ការដាក់ពាក្យបណ្តឹង

តើអ្នកមានការព្រួយបារម្ភអំពីវិធីទាក់ទងអ្នកដោយសមាជិកម្នាក់នៃក្រសួងប៉ូលីស Greensboro ដែរឬទេ? អ្នកអាចដាក់ពាក្យបណ្តឹងជាមួយផ្នែកស្តង់ដារវិជ្ជាជីវៈរបស់ GPD ដោយប្រើវិធី 4 យ៉ាងដូចខាងក្រោម។

**336-373-2468**

ម៉ោង 8 ព្រឹកដល់ 5 ល្ងាច
ថ្ងៃច័ន្ទដល់សុក្រ

ទម្រង់បែបបទពាក្យបណ្តឹងតាមអនឡាញ

**greensboro-nc.gov/ComplaintForm**

ផ្នែកស្តង់ដារវិជ្ជាជីវៈ

**100 E Police Plaza**
**Greensboro, NC 27401**
ម៉ោង 8 ព្រឹកដល់ 5 ល្ងាច
ថ្ងៃច័ន្ទដល់សុក្រ

ទម្រង់បែបបទពាក្យបណ្តឹងតាមសំបុត្រ

បោះពុម្ព និងបំពេញទម្រង់បែបបទពាក្យបណ្តឹងតាមអនឡាញនៅលើគេហទំព័រ
*greensboro-nc.gov/ComplaintForm*
ហើយផ្ញើទៅ៖
**Greensboro Police Department**
**Professional Standards Division**
**100 E Police Plaza**
**Greensboro, NC 27401**

## មិនពេញចិត្តនឹងសេចក្តីសម្រេចចិត្តរបស់ PSD ឬ?

ប្រសិនបើអ្នកមិនពេញចិត្តនឹងសេចក្តីសម្រេចចិត្តរបស់ PSD ទេ អ្នកអាចប្តឹងឧទ្ធរណ៍ចំពោះការសម្រេចចិត្តនេះទៅកាន PCRB ដើម្បីស្នើសុំការពិនិត្យឡើងវិញ។ បណ្តឹងឧទ្ធរណ៍ត្រូវតែដាក់ក្នុងរយៈពេល 30 ថ្ងៃគិតចាប់ពីថ្ងៃទទួលបានលិខិតអំពីសេចក្តីសម្រេចចិត្តរបស់ PSD ត្រូវបានផ្ញើទៅអ្នក។ បន្ទាប់មក PCRB នឹងពិនិត្យមើលរាល់ព័ត៌មានពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ត្រឹមឯកសារស៊ើបអង្កេតរបស់ PSD វីដេអូកាមេរ៉ាបំពាក់លើខ្លួន និងព័ត៌មានផ្សេងទៀតដែលអ្នកយល់ថាពាក់ព័ន្ធ។ ចំពោះបណ្តឹងឧទ្ធរណ៍ទាន់ពេលវេលាដែលបានដាក់នៅ PCRB បញ្ហានេះនឹងត្រូវពិនិត្យឡើងវិញដោយក្រុមប្រឹក្សាភិបាលក្នុងរយៈពេល 60 ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីព្រាងចុងក្រោយនៃបណ្តឹងឧទ្ធរណ៍របស់អ្នក។

មានសំណួរទេ?

**Latisha McNeil,** អ្នកគ្រប់គ្រង ***GCJAC***
336-373-2295 ឬ GCJAC@greensboro-nc.gov

**GCJAC** ក្រុមប្រឹក្សាយុត្តិធម៌ព្រហ្មទណ្ឌ **GCJAC**

តាមដាន ពិនិត្យឡើងវិញ វិភាគ អប់រំ ផ្តល់យោបល់ រាយការណ៍។